# បុដទូសកជាតក



*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធកុមារ ដែលប្រទូសកញ្ចប់ម្នាក់ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **អទ្ធា ហិ ឆ្វូន មិគរាជា** *ដូច្នេះជាដើម ។*

*បានឮមកថា ក្នុងក្រុងសាវត្ថី អាមាត្យម្នាក់និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យគង់ក្នុងឧទ្យាន កាលថ្វាយទាន គាត់ពោលថា ក្នុងចន្លោះពេលភត្ត បើព្រះមានព្រះភាគ និងលោកម្ចាស់ប្រាថ្នានឹងត្រាច់មើល ចូរនិមន្តចុះ ។ ភិក្ខុទាំងឡាយត្រាច់ចារិកក្នុងឧទ្យាន ។*

*ក្នុងខណៈនោះ ឧទ្យានបាលឡើងលើដើមឈើដែលមានស្លឹកច្រើន បេះស្លឹកឈើធំៗ មកធ្វើជាកញ្ចប់ ដោយគិតថា នេះនឹងជាកញ្ចប់ផ្កាឈើ នេះនឹងជាកញ្ចប់ផ្លែឈើ ដូច្នេះហើយ ទើបទម្លាក់កញ្ចប់ឲ្យធ្លាក់ចុះត្រង់គល់ឈើ ។ កូនរបស់គាត់កម្ទេចកញ្ចប់កញ្ចប់ ដែលធ្លាក់មកហើយៗ ។ ភិក្ខុទាំងឡាយប្រាប់រឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះសាស្តាត្រាស់ថា ម្នាល*

ភិក្ខុទាំងឡាយ  មិនមែនតែក្នុងកាលឥឡូវនេះទេ  សូម្បីក្នុងកាលមុន  ក្មេងនេះក៏ប្រទូសនឹងកញ្ចប់ដែរ រួចហើយទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល  កាលព្រះបាទព្រហ្មសោយរាជសម្បត្តិ  ក្នុងនគរពារាណសី,  ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍មួយ កាលធំហើយ ក៏នៅគ្រប់គ្រងផ្ទះ ។ ថ្ងៃមួយ លោកទៅឧទ្យានដោយករណីយកិច្ចយ៉ាងណាមួយ ។ ក្នុងឧទ្យាននោះ មានស្វាជាច្រើនរស់នៅ ។

ឧទ្យានបាលទម្លាក់កញ្ចប់ស្លឹកឈើ  តាមនិយាយមុននោះឯង,  ស្វាជាប្រធានកម្ទេចកញ្ចប់ដែលធ្លាក់មកហើយៗ ។ ព្រះពោធិសត្វហៅស្វានោះ មកពោលថា អ្នកប្រទូសកញ្ចប់ដែលឧទ្យានបាលទម្លាក់មកហើយៗ ដោយប្រាថ្នានឹងធ្វើឲ្យជាទីពេញចិត្ត ដ៏ក្រៃលែង ដូច្នេះ ព្រះពោធិសត្វក៏ពោលគាថាទី ១ ថា

**អទ្ធា ហិ នូន មិគរាជា,  បុដកម្មស្ស កោវិទោ;**
**តថា ហិ បុដំ ទូសេតិ,  អញ្ញំ នូន ការិស្សតិ។**

មិគរាជ  គឺស្តេចស្វា  ជាសត្វឈ្លាសក្នុងការធ្វើកញ្ចប់ស្លឹកឈើដោយពិត  ព្រោះហេតុដូច្នោះ ទើបបានបំផ្លាញកញ្ចប់ចោល នឹងធ្វើកញ្ចប់ដទៃ ឲ្យល្អជាងកញ្ចប់មុន ដោយពិត ។

បណ្តាបទទាំងនោះ បទថា **មិគរាជា** សេចក្តីថា ព្រះពោធិសត្វពោលសរសើរស្វា ។

ស្វាស្តាប់ពាក្យនោះហើយ ពោលគាថាទី ២ ថា

**ន មេ មាតា វា បិតា វា,  បុដកម្មស្ស កោវិទោ;**
**កតំ កតំ ខោ ទូសេម,  ឯវំ ធម្មមិទំ កុលំ។**

*បិតាឬមាតារបស់ខ្ញុំ មិនមែនជាសត្វឈ្លាស ក្នុងការធ្វើកញ្ចប់ទេ តែពួកខ្ញុំ បានតែខាង បំផ្លាញនូវវត្ថុដែលគេធ្វើហើយ ៗ ប៉ុណ្ណោះ នេះជាត្រកូល (របស់ពានរ) តែងមានយ៉ាងនេះ ជាធម្មតា ។*

*ព្រះពោធិសត្វស្ដាប់ពាក្យនោះហើយ ពោលគាថាទី ៣ ថា*

**យេសំ វោ ឯទិសោ ធម្មោ, អធម្មោ បន កីទិសោ;**
**មា វោ ធម្មំ អធម្មំ វា, អទ្ទសាម កុទាចនំ។**

*ធម្មតារបស់ពួកអ្នកណា ប្រាកដយ៉ាងនេះទៅហើយ ចំណង់បើ មិនមែនធម្មតា តើនឹងដូចម្ដេចទៅវិញ យើងសូមកុំឲ្យជួបប្រទះនឹងអាការជាធម្មតា ឬមិនមែនជាធម្មតា របស់ពួកអ្នកនោះ ក្នុងកាលណាឡើយ ។*

*កាលព្រះពោធិសត្វពោលយ៉ាងនេះហើយ ក៏តិះដៀលហ្វូងស្វាម្ដងទៀត ហើយចៀសចេញទៅ ។*

*ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ និងប្រជុំជាតកថា*

**តទា វានរោ បុដទូសកទារកោ អហោសិ** *ស្វាក្នុងកាលនោះ បានមកជាកុមារប្រទូសកញ្ចប់*

**បណ្ឌិតបុរិសោ បន អហមេវ អហោសឹ** *ចំណែកបុរសបណ្ឌិត គឺតថាគតនេះឯង ។*

*បុដទូសកជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តិកនិបាត ឧទបានវគ្គ)*

*ដោយសដវថ*